**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៨)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៧ ០២៨នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ ដើម្បីចៀសវាងការលំបាកក្នុងការបង្វិលថវិកាសងរាជរដ្ឋាភិបាលវិញ ក្នុងករណីរោងចក្រ សហគ្រាសសុំចូលធ្វើការមុនកាលកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ នោះប្រាក់ឧបត្ថម្ភនឹងត្រូវចែកចេញជា ២ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងារចាប់ពី ២១ថ្ងៃ ដល់ ១ខែ, និងត្រូវបែងចែកជា ៤ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដោយក្នុង ១ដង ស្មើនឹងថវិកាចំនួន ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក)។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីង ដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ប្រញាល់... សូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៤៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 28 |
| 1 | ក្រុមហ៊ុនប៊ីយូធី ស៊ីល ស្រ្គីន លីមីធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុនម៉ាកាឡូត ហ្គាមេន (ខេមបូឌា) សាខាទី ១ | ភ្នំពេញ |
| 3 | ក្រុមហ៊ុនស៊ីនចាង ថេក អ៊ីន | ភ្នំពេញ |
| 4 | ក្រុមហ៊ុនឈាន ឈុន ហ្វូង ជា ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុនហុង ជា (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុនសាន់ វ៉ាន់ (ខេមបូឌា) ហ្គាម៉ិន | ភ្នំពេញ |
| 7 | ក្រុមហ៊ុនស៊ីន ស៊ី អេក អិន ហុង(ខេមបូឌា)ប្លាស្ទិក អ៊ិនដាស្ទ្រី | ភ្នំពេញ |
| 8 | ក្រុមហ៊ុនធី&ខេ ហ្គាមេន អ៊ីនដាស្ទ្រី | ភ្នំពេញ |
| 9 | ក្រុមហ៊ុនប៉ុលតិច អ៊ិនដាសស្ទ្រីល (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 10 | ក្រុមហ៊ុនឌូហីស្ក(ខេមបូឌា) | ភ្នំពេញ |
| 11 | ក្រុមហ៊ុនស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុនអេហ្វ អឹម អេហ្វ មេនូហ្វេកធឺរីង ឯ.ក. | កណ្តាល |
| 13 | ក្រុមហ៊ុនហ័ង ខាន មេធៀរៀល ឯ.ក | កណ្តាល |
| 14 | ក្រុមហ៊ុនហ៊ីង ង៉ៃ លេឌើរវែរ(ខេមបូឌា)ហ្វេកធើរី | កណ្តាល |
| 15 | ក្រុមហ៊ុនអេសអ៊ីអ៊ីអេស គ្លូបល(ខេមបូឌា)ខូ អិលធីឌី | កណ្តាល |
| 16 | ក្រុមហ៊ុនស៊ីអិនឌីហ្វ្រើ អិនធើណេសិនណល (ខេមអេច) ឯ.ក | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុនហ៊ប គឹង (ខេមបូឌា)មេនូហ្វេកឆឺរីង ឯ.ក | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុនហ័រសេងដារ ហ្វ៊ីបភើ (ខេម) | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុនញូអេធីធី ស៊ូ ម៉េកឃីង (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុនហៃនថុន ឡាក់ហ្គេត (ខេមបូឌា) ឯ ក | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុនម៉ូណូភា (ខេមបូឌា) | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុនស្រ្តង ហែលធ៍ អ៊ិនធើណេសិនណល លីមីធីត | តាកែវ |
| 23 | ក្រុមហ៊ុនហុង សេន ថេកស្តាយ(ខេមបូឌា) ខូអិលធីឌី | តាកែវ |
| 24 | ក្រុមហ៊ុនខតចិនខនសិប អ៊ិនដាសស្ទ្រី ឯ.ក | តាកែវ |
| 25 | ក្រុមហ៊ុនអ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 26 | ក្រុមហ៊ុនតូកូកូសេន ហ្គាមេន (ខេមបូឌា) | ស្វាយរៀង |
| 27 | ក្រុមហ៊ុនវ៉ាន់ធីជ រីវើរ ថេកស្តាយ | ព្រះសីហនុ |
| 28 | ក្រុមហ៊ុនជីនចេនយ៉ន(ខេមបូឌា) | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 16 |
| 29 | ក្រុមហ៊ុនហ្វ៊ូជឡាយហ្វ៍ ឯ.ក | ភ្នំពេញ |
| 30 | ក្រុមហ៊ុនអលមិន ខូ អិលធីឌី | ភ្នំពេញ |
| 31 | ក្រុមហ៊ុនវើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 32 | ក្រុមហ៊ុនទេសចរណ៍វើលដ៏អិចប្រេស | ភ្នំពេញ |
| 33 | ក្រុមហ៊ុនវីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 34 | ក្រុមហ៊ុនណាហ្គាវើលដ៍ លីមីធីត | ភ្នំពេញ |
| 35 | ក្រុមហ៊ុន ឥណ្ឌូឆាយណា សឺវីសេស (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 36 | ក្រុមហ៊ុន ដឹ ប្លែក សាន់ រេសថឺរេន អេន បារ ខូ អិលធីឌី | សៀមរាប |
| 37 | ក្រុមហ៊ុនអានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 38 | ក្រុមហ៊ុនសារ៉េរីសត និង ស្ប៉ា | សៀមរាប |
| 39 | ក្រុមហ៊ុនគ្រេហ្ស៊ី អូអេស៊ីស | សៀមរាប |
| 40 | ក្រុមហ៊ុនឌីណាតា អង្គរ | សៀមរាប |
| 41 | ក្រុមហ៊ុនលីនរតនៈអង្គរ | សៀមរាប |

| ល.រ | ឈ្មោះពេទ្យចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 42 | សណ្ឋាគារ អង្គរ | សៀមរាប |
| 43 | ក្រុមហ៊ុនហាទៀន វីហ្គាស អេនធើធេនមេន រីហ្សត | កំពត |
| 44 | ក្រុមហ៊ុនរមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |